# ព្រះរាជក្រម

នស/រកម/០១០៦/០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុសញ្ញា
# ស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលសន្និសីទទូទៅលើកទី ៣២ នៃអង្គការយូណេស្កូអនុម័តនាថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ នៅទីក្រុងប៉ារីស ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦

នរណ.០១០១.០២១ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ព្រះហស្តលេខា**

**ស៊ីសុវត្ថិ ប៉ាណារ៉ា ស៊ីរីវុឌ្ឍ**

លេខ: ៣១៩ . ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សរឌី តាន់**

# អនុសញ្ញា
# ស្តីពី
# ការការពារបេតិកភណ្ឌវប្បធម៌អរូបី

សន្និសីទទូទៅរបស់អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ដែលហៅកាត់ថា អង្គការយូណេស្កូ បានប្រជុំនៅទីក្រុងប៉ារីស ចាប់ពីថ្ងៃទី ២៩ ខែ កញ្ញា ដល់ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ នៃសម័យប្រជុំលើកទី ៣២

យោងលិខិតូបករណ៍អន្តរជាតិដែលមានស្រាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជាពិសេសសេចក្តីថ្លែងការណ៍ ជាសាកល អំពីសិទ្ធិមនុស្សនៅឆ្នាំ ១៩៤៨ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នាឆ្នាំ ១៩៦៦ ហើយនិងកតិកាសញ្ញាស្តីពីច្បាប់រដ្ឋប្បវេណី និងនយោបាយនាឆ្នាំ ១៩៦៦

ដោយឃើញនូវសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបីគឺជាមូលដ្ឋានគ្រឹះនៃវប្បធម៌ចម្រុះ និងជាការធានានូវកិច្ចអភិវឌ្ឍន៍ដោយចីរភាព ដូចបានគូសបញ្ជាក់នៅក្នុងអនុសាសន៍របស់អង្គការយូណេស្កូស្តីពីការការពារវប្បធម៌ប្រពៃណី និងប្រជាជននាឆ្នាំ ១៩៨៩ នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលរបស់អង្គការយូណេស្កូស្តីពីភាពប្លែកគ្នារបស់វប្បធម៌នាឆ្នាំ ២០០១ ហើយនិងនៅក្នុងសេចក្តីថ្លែងការណ៍នៅទីក្រុងអ៊ីស្តង់ប៊ុលនាឆ្នាំ២០០២ ដែលត្រូវបានអនុម័ត នៅក្នុងកិច្ចប្រជុំតុមូលលើកទី៣ របស់រដ្ឋមន្ត្រីវប្បធម៌នៃប្រទេសទាំងឡាយ

ដោយឃើញនូវទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅ រវាងបេតិកភណ្ឌវប្បធម៌អរូបី ហើយ និងបេតិកភណ្ឌវប្បធម៌រូបីនិងធម្មជាតិ

ដោយទទួលស្គាល់ថាដំណើរការសាកលភាវូបនីយកម្ម និងការប្រែប្រួលរបស់សង្គម ជាមួយនឹងលក្ខខណ្ឌដែលបង្កើតឱ្យមានការពិគ្រោះគ្នាសារជាថ្មីរវាងសហគមន៍នានា ក៏ដូចជាបាតុភូតនៃការមិនចេះយោគយល់គ្នាដែលបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរក្លាយជាគ្រោះខូចខាត ការបាត់បង់ និងការបំផ្លិចបំផ្លាញទៅលើបេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសដោយសារកង្វះខាតមធ្យោបាយសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះផង

ដោយចាប់អារម្មណ៍ដល់ឆន្ទៈជាសាកល និងការរួមគ្នាយកចិត្តទុកដាក់ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ

ដោយទទួលស្គាល់ថាបណ្តាសហគមន៍ ជាពិសេសសហគមន៍ជនជាតិដើម ក្រុមមនុស្ស និងបុគ្គលនៅក្នុងករណីចាំបាច់ខ្លះមានតួនាទីយ៉ាងសំខាន់ក្នុងការងារផលិត ការការពារ ការថែទាំ និងការបង្កើតសារជាថ្មីនូវបេតិកភណ្ឌវប្បធម៌អរូបី ញ៉ាំងឱ្យវប្បធម៌ច្រើនបែបកើនឡើងព្រមទាំងការច្នៃប្រឌិតរបស់មនុស្សផង

ដោយកត់សម្គាល់នូវលទ្ធភាពធំធេងរបស់សកម្មភាព ដែលដឹកនាំដោយ អង្គការយូណេស្កូ ក្នុងការបង្កើតលិខិតូបករណ៍ដែលមានលក្ខណៈជាបទដ្ឋានសំដៅរក្សាការពារបេតិកភណ្ឌវប្បធម៌ ជាពិសេសអនុសញ្ញាសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ពិភពលោកនិងបេតិកភណ្ឌវប្បធម៌ធម្មជាតិនាឆ្នាំ ១៩៧២

ដោយកត់សម្គាល់ម្យ៉ាងទៀតថា រហូតមកដល់បច្ចុប្បន្ននេះនៅមិនទាន់មានលិខិតូបករណ៍ពហុភាគី ដែលមានលក្ខណៈបង្ខិតបង្ខំណាមួយសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបីនៅឡើយ

ដោយឃើញថាកិច្ចព្រមព្រៀងទាំងឡាយ អនុសាសន៍នានា និងសេចក្តីសម្រេចចិត្តអន្តរជាតិដែល កំពុងមាន អត្ថិភាពស្តីពីបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិដែលចាំបាច់ត្រូវតែធ្វើឱ្យកាន់តែសម្បូរឡើង និងបំពេញ បន្ថែមប្រកបដោយប្រសិទ្ធភាព តាមមធ្យោបាយបន្ថែមបទប្បញ្ញត្តិថ្មីៗទៀតពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌អរូបី

ដោយឃើញនូវភាពចាំបាច់ ដើម្បីទាក់ទាញឱ្យមានការចាប់អារម្មណ៍បន្ថែមទៀត ជាពិសេសក្នុងចំណោម មនុស្សជំនាន់ក្រោយទៅលើសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបីនិងការការពារបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ

ដោយឃើញថាសហគមន៍អន្តរជាតិត្រូវតែរួមចំណែកជាមួយភាគីនៃអនុសញ្ញានេះ ដើម្បីការពារ បេតិកភណ្ឌវប្បធម៌ទាំងនោះ ដោយឈរលើស្មារតីសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក

ដោយរំលឹកដល់កម្មវិធីរបស់អង្គការយូណេស្កូ ស្តីពីបេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសគឺការប្រកាសអំពី ស្នាដៃឯកនៃបេតិកភណ្ឌសំដី និងអរូបីរបស់មនុស្សជាតិ

ដោយឃើញនូវតួនាទីមិនអាចកាត់ថ្លៃបានរបស់បេតិកភណ្ឌវប្បធម៌អរូបី ដូចជាកត្តាសម្រាប់ធ្វើឱ្យ មនុស្សគ្រប់រូបខិតចូលជិតគ្នា និងផ្លាស់ប្តូរ និងការយោគយល់គ្នារវាងមនុស្សជាតិ

អនុម័តអនុសញ្ញានេះនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា១ . គោលបំណងរបស់អនុសញ្ញា

គោលបំណងរបស់អនុសញ្ញានេះគឺ:

ក-ការពារបេតិកភណ្ឌវប្បធម៌អរូបី

ខ-គោរពចំពោះបេតិកភណ្ឌវប្បធម៌អរូបីរបស់សហគមន៍ ក្រុមមនុស្ស និងបុគ្គលដែលពាក់ព័ន្ធ

គ-ទាក់ទាញឱ្យមានការចាប់អារម្មណ៍ក្នុងកម្រិតនៅនឹងកន្លែង កម្រិតជាតិ និងកម្រិតអន្តរជាតិ ចំពោះ សារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបី ហើយការចូលរួមវាយតម្លៃលើបេតិកភណ្ឌវប្បធម៌អរូបីនោះ

ឃ. កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ ។

មាត្រា២ *និយមន័យ*

សម្រាប់អនុសញ្ញានេះ :

១. ពាក្យ " បេតិកភណ្ឌវប្បធម៌អរូបី " មានន័យថា ការប្រតិបត្តិ ការសម្តែង ការនិយាយ ចំណេះដឹង ចំណេះធ្វើ ព្រមទាំងឧបករណ៍វត្ថុ វត្ថុដែលមានប្រភពសិប្បនិម្មិត និងលំហវប្បធម៌បញ្ចូលគ្នា ដែលសហគមន៍ ក្រុមមនុស្ស និងក្នុងករណីខ្លះ បុគ្គលទទួលស្គាល់ថាជាផ្នែកមួយនៃបេតិកភណ្ឌវប្បធម៌របស់ពួកគេ ។ បេតិកភណ្ឌវប្បធម៌អរូបីនេះ ត្រូវបានបន្តវេនពីជំនាន់មួយទៅជំនាន់មួយ ហើយដែលត្រូវបានបង្កើតថ្មីឡើងវិញ ជាអចិន្ត្រៃយ៍ដោយសហគមន៍ និងក្រុមមនុស្សផ្អែកទៅតាមកន្លែងនិងបរិស្ថានដែលគេរស់នៅ ទៅនឹងអន្តរកម្មរបស់ពួកគេជាមួយនឹងធម្មជាតិ ព្រមទាំងជាមួយនឹងប្រវត្តិសាស្ត្ររបស់ពួកគេហើយបានផ្តល់នូវមនោសញ្ចេតនានៃអត្តសញ្ញាណ និងនិរន្តរភាព សម្រាប់រួមចំណែកក្នុងការជំរុញឱ្យមានការគោរពវប្បធម៌ប្លែកៗគ្នា និងភាពចេះបង្កើតថ្មីរបស់មនុស្ស ។ ក្នុងអនុសញ្ញានេះ អាចចាត់ទុកវាជាបេតិកភណ្ឌវប្បធម៌អរូបីគឺរបស់ដែលសមស្របជាមួយនឹងលិខិតូបករណ៍អន្តរជាតិកំពុងអត្ថិភាពទាក់ទងជាមួយនិងសិទ្ធិមនុស្សជាធរមានក៏ដូចជាការតម្រូវឱ្យមានការគោរពគ្នាទៅវិញទៅមកក្នុងរវាងសហគមន៍ រវាងក្រុមមនុស្ស បុគ្គល និងការអភិវឌ្ឍប្រកបដោយចីរភាព ។

២. ពាក្យ " បេតិកភណ្ឌវប្បធម៌អរូបី " តាមនិយមន័យក្នុងកថាខណ្ឌទី១ខាងលើត្រូវបានស្តែងឡើងជាពិសេសនៅក្នុងវិស័យដូចខាងក្រោម :

ក-ប្រពៃណីនិងសំដីនិយាយ រួមមាន ភាសា ជាយាននៃបេតិកភណ្ឌវប្បធម៌អរូបី

ខ-សិល្បៈទស្សនីយភាព

គ-ការប្រតិបត្តិសង្គម សាសនា និងប្រតិបត្តិការណ៍សម្រាប់ពិធីបុណ្យ

ឃ-ចំណេះដឹង និងការប្រតិបត្តិស្តីអំពីធម្មជាតិ និងសាកលលោក

ង-ចំណេះធ្វើផ្សារភ្ជាប់ជាមួយនឹងសិប្បកម្មប្រពៃណី ។

៣. ពាក្យ " ការពារ " មានន័យថា វិធានការសំដៅធានាភាពគង់វង្សនៃបេតិកភណ្ឌវប្បធម៌អរូបី រួមទាំងការរៀបអត្តសញ្ញាណ ការទុកឯកសារ ការស្រាវជ្រាវ ការថែរក្សាការពារ ការលើកតម្កើង ការធ្វើឱ្យមានតម្លៃ ការផ្ទេរបន្ត ជាពិសេសតាមរយៈការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ក៏ដូចជាការធ្វើឱ្យមានជីវិតឡើងវិញនូវទិដ្ឋភាពនានានៃបេតិកភណ្ឌវប្បធម៌ទាំងនោះ ។

៤. ពាក្យ " រដ្ឋភាគី " គឺរដ្ឋទាំងឡាយដែលផ្សារភ្ជាប់ជាមួយអនុសញ្ញានេះ ហើយរដ្ឋទាំងនោះធ្វើឱ្យអនុសញ្ញានេះចូលជាធរមាន ។

៥. អនុសញ្ញានេះអនុវត្តស្របតាមគោលការណ៍ផ្លាស់ប្តូរជាចាំបាច់ mutatis mutandis នៅលើទឹកដីតាមខ្លឹមសារមាត្រា ៣៣ ដែលក្លាយជាភាគីនៃអនុសញ្ញា សមស្របតាមលក្ខខណ្ឌដូចបានបញ្ជាក់នៅក្នុងមាត្រា នោះ ។ ក្នុងករណីនេះពាក្យថា រដ្ឋភាគីមានន័យថាទឹកដី ទាំងនោះដូចគ្នា ។

មាត្រា ៣ . - ទំនាក់ទំនងជាមួយលិខិតូបករណ៍អន្តរជាតិផ្សេងទៀត

ប្រការដែលមានចែងនៅក្នុងអនុសញ្ញានេះហើយមិនអាចបកស្រាយបាន :

ក.ការធ្វើឱ្យខូចខាតដល់លក្ខន្តិកៈ ឬការបន្ថយនូវកម្រិតនៃការការពារទ្រព្យដែលត្រូវបានប្រកាសថាជាបេតិកភណ្ឌវប្បធម៌ពិភពលោកនៅក្នុងក្របខណ្ឌនៃអនុសញ្ញាឆ្នាំ ១៩៧២ ស្តីពី ការការពារបេតិកភណ្ឌវប្បធម៌ពិភពលោក និងបេតិកភណ្ឌវប្បធម៌ធម្មជាតិដែលនៅក្នុងនោះកត្តាមួយនៃបេតិកភណ្ឌវប្បធម៌អរូបីមានការទាក់ទងដោយផ្ទាល់ ឬ

ខ.ការផ្តល់សិទ្ធិនិងកាតព្វកិច្ចឱ្យរដ្ឋមួយភាគីនូវអ្វីដែលលិខិតូបករណ៍អន្តរជាតិបានកំណត់ទាក់ទងជាមួយសិទ្ធិលើកម្មសិទ្ធិបញ្ញា ឬទាក់ទងជាមួយការប្រើប្រាស់ប្រភពធនធានខាងជីវសាស្ត្រ និងបរិស្ថានដែលរដ្ឋទាំងនោះជាភាគី ។

## ជំពូកទី២

## អង្គការរបស់អនុសញ្ញា

មាត្រា ៤ .- *មហាសន្និបាតរបស់រដ្ឋភាគី*

១. ត្រូវបានបង្កើតមហាសន្និបាតរបស់រដ្ឋភាគីហៅថា " មហាសន្និបាត " ។ មហាសន្និបាតនេះគឺជាអង្គការអធិបតេយ្យរបស់អនុសញ្ញានេះ ។

២. មហាសន្និបាតត្រូវបើកអង្គប្រជុំសាមញ្ញរៀងរាល់២ឆ្នាំម្តង ។ មហាសន្និបាតនេះអាចបើកអង្គប្រជុំវិសាមញ្ញនៅពេលដែលមហាសន្និបាតសម្រេច ឬក៏តាមការស្នើសុំរបស់គណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌អរូបី ឬយ៉ាងហោចណាស់មានសំឡេងតាមការស្នើសុំពីចំនួន ១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគី ។

៣. មហាសន្និបាតអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

មាត្រា ៥ .- គណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការការពារ បេតិកភណ្ឌវប្បធម៌អរូបី

១. ត្រូវបង្កើតគណៈកម្មាធិការអន្តររដ្ឋាភិបាលសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបីមួយនៅជាមួយអង្គការយូណេស្កូ នេះហៅថា " គណៈកម្មាធិការ " ។ សមាសភាពគណៈកម្មាធិការនេះមានតំណាងមកពី១៨រដ្ឋភាគីដែលជ្រើសតាំងឡើងដោយមហាសន្និបាតនៃរដ្ឋជាភាគី បន្ទាប់ពីអនុសញ្ញានេះចូលជាធរមានស្របតាមមាត្រា ៣៤ ។

២. ចំនួនរដ្ឋជាសមាជិករបស់គណៈកម្មាធិការនេះអាចឡើងទៅដល់ចំនួន ២៤ នៅពេលដែលចំនួនរដ្ឋភាគីទាំងអស់របស់អនុសញ្ញានេះកើនឡើងដល់ចំនួន ៥០ ។

មាត្រា ៦ .- ការបោះឆ្នោត និងអាណត្តិរបស់រដ្ឋជាសមាជិកគណៈកម្មាធិការ

១. ការបោះឆ្នោតជ្រើសតាំងរដ្ឋសមាជិករបស់គណៈកម្មាធិការ ត្រូវគោរពតាមគោលការណ៍បែងចែកភូមិសាស្ត្រនិងការផ្លាស់វេនគ្នាដោយសមធម៌ ។

២. រដ្ឋសមាជិករបស់គណៈកម្មាធិការ ត្រូវបានជ្រើសតាំងឡើងសម្រាប់អាណត្តិ៤ឆ្នាំដោយរដ្ឋភាគីរបស់អនុសញ្ញានៅក្នុងមហាសន្និបាត ។

៣ ជានិច្ចកាល អាណត្តិរបស់ចំនួនពាក់កណ្តាលរដ្ឋសមាជិករបស់គណៈកម្មាធិការដែលត្រូវបានជ្រើសតាំងនៅក្នុងការបោះឆ្នោតលើកទី១ ត្រូវបានកម្រិតត្រឹម ២ឆ្នាំ ។ រដ្ឋទាំងនោះ ត្រូវបានចាត់តាំងតាមការចាប់ឆ្នោតនៅក្នុង ឱកាសបោះឆ្នោតលើកទី១នោះ ។

៤. រៀងរាល់រយៈពេល២ឆ្នាំ មហាសន្និបាតត្រូវរៀបចំផ្លាស់ប្តូរជាថ្មីនូវរដ្ឋសមាជិកចំនួនពាក់កណ្តាលនៃគណៈកម្មាធិការ ។

៥. មហាសន្និបាតបោះឆ្នោតជ្រើសតាំងរដ្ឋសមាជិករបស់គណៈកម្មាធិការ ទៅតាមចំនួនដទៃទៀតចាំបាច់សម្រាប់បំពេញតំណែងដែលនៅទំនេរ ។

៦. រដ្ឋសមាជិកមួយរបស់គណៈកម្មាធិការអាចត្រូវបានជ្រើសតាំង សម្រាប់តែរយៈពេល២អាណត្តិជាប់ៗគ្នា ។

៧. រដ្ឋសមាជិករបស់គណៈកម្មាធិការជ្រើសរើសអ្នកមានជំនាញដើម្បីជាតំណាងនៅក្នុងវិស័យផ្សេងៗនៃ បេតិកភណ្ឌវប្បធម៌អរូបី ។

មាត្រា ៧ .- មុខងាររបស់គណៈកម្មាធិការ

ដោយពុំប៉ះពាល់ដល់ភារកិច្ចដទៃទៀត ដែលបច្ចុប្បន្នអនុសញ្ញាបានប្រគល់មុខងារឱ្យគណៈកម្មាធិការមានដូចតទៅ ÷

ក. បំផុសគោលដៅរបស់អនុសញ្ញា លើកទឹកចិត្ត និងធានាការតាមដានដំណើរការអនុវត្តអនុសញ្ញានេះ

ខ. ផ្តល់យោបល់ចំពោះប្រតិបត្តិការល្អ និងបង្កើតជាអនុសាសន៍លើវិធានការនានាដើម្បីការពារ បេតិកភណ្ឌវប្បធម៌អរូបី

គ.រៀបចំនិងដាក់ជូនមហាសន្និបាតអនុម័តនូវគម្រោងផែនការសម្រាប់ការប្រើប្រាស់ប្រភពមូលនិធិស្របតាមមាត្រា ២៥

ឃ. ខិតខំរកមធ្យោបាយដើម្បីបង្កើនធនធាន និងចាត់វិធានការសមស្របទាំងឡាយដើម្បីសម្រេចគោលដៅនេះស្របតាមមាត្រា ២៥

ង. រៀបចំនិងដាក់ជូនមហាសន្និបាតអនុម័តនូវការណែនាំប្រតិបត្តិទាំងឡាយសម្រាប់ដំណើរការអនុវត្តអនុសញ្ញានេះ

ច. ពិនិត្យ ដោយផ្អែកលើមាត្រា២៩ នូវរបាយការណ៍ដែលរដ្ឋភាគីបានផ្ញើមក ហើយនិងសង្ខេបរបាយការណ៍ទាំងនោះ ដាក់ជូនមហាសន្និបាត

ឆ.ពិនិត្យរាល់សំណើដែលរដ្ឋភាគីទាំងអស់ស្នើសុំ ហើយសម្រេចអនុលោមតាមគោលការណ៍សត្យានុម័តនៃការជ្រើសរើស ហើយដែលបានទទួលការយល់ព្រមពីមហាសន្និបាត :

១. ចុះក្នុងបញ្ជី និងសេចក្តីស្នើដូចមានចែងនៅក្នុងមាត្រា ១៦. ១៧ និង ១៨

២. ផ្តល់ជំនួយឧបត្ថម្ភអន្តរជាតិស្របតាមមាត្រា ២២ ។

មាត្រា ៨ .- របៀបធ្វើការរបស់គណៈកម្មាធិការ

១. គណៈកម្មាធិការទទួលខុសត្រូវចំពោះមុខមហាសន្និបាត។ គណៈកម្មាធិការត្រូវរាយការណ៍ជូនមហាសន្និបាតនូវរាល់សកម្មភាពនិងការសម្រេចរបស់ខ្លួន។

២. គណៈកម្មាធិការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយសំឡេង ២ភាគ៣ នៃចំនួនសមាជិករបស់ខ្លួន។

៣. គណៈកម្មាធិការអាចបង្កើតជាបណ្តោះអាសន្ននូវអង្គការពិគ្រោះយោបល់អាដហុក " Ad hoc" ចំពោះកិច្ចការ ដែលខ្លួនយល់ឃើញថាចាំបាច់ សម្រាប់ការបំពេញមុខងាររបស់ខ្លួន។

៤. គណៈកម្មាធិការអាចអញ្ជើញអង្គការសាធារណៈដទៃទៀត ឬឯកជនក៏ដូចជារូបវន្តបុគ្គលដែលមានសមត្ថភាពហើយត្រូវបានគេទទួលស្គាល់នៅក្នុងវិស័យនៃបេតិកភណ្ឌវប្បធម៌អរូបី ឱ្យចូលរួមប្រជុំជាមួយដើម្បីសុំយោបល់ចំពោះបញ្ហាពិសេសដោយឡែកនានា។

មាត្រា ៩ .- ការតែងតាំងអង្គការពិគ្រោះយោបល់

១. គណៈកម្មាធិការស្នើទៅមហាសន្និបាត សុំតែងតាំងអង្គការក្រៅរដ្ឋាភិបាលនានាដែលមានសមត្ថភាពហើយគេទទួលស្គាល់ នៅក្នុងវិស័យនៃបេតិកភណ្ឌវប្បធម៌អរូបី អង្គការទាំងនោះមានមុខងារ ជាអ្នកផ្តល់យោបល់ដល់គណៈកម្មាធិការ។

២. គណៈកម្មាធិការស្នើទៅមហាសន្និបាតអំពីលក្ខខណ្ឌ និងបែបបទនៃការតែងតាំងអង្គការខាងលើនេះ។

មាត្រា ១០ .- អគ្គលេខាធិការដ្ឋាន

១. គណៈកម្មាធិការមាន អគ្គលេខាធិការដ្ឋាននៃអង្គការយូណេស្កូជួយធ្វើការ។

២. អគ្គលេខាធិការដ្ឋានត្រៀមរៀបចំឯកសាររបស់មហាសន្និបាតនិងរបស់គណៈកម្មាធិការក៏ដូចជាធ្វើសេចក្តីព្រាងរបៀបវារៈនៃការប្រជុំទាំងឡាយ និងធានាការអនុវត្តសេចក្តីសម្រេចនៃការប្រជុំទាំងនោះ ។

## ជំពូកទី ៣

## ការការពារបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងកម្រិតថ្នាក់ជាតិ

មាត្រា ១១ .- តួនាទីរបស់រដ្ឋភាគី

តួនាទីនេះគឺជារបស់រដ្ឋភាគីនីមួយៗ:

ក.ចាត់វិធានការចាំបាច់ ដើម្បីពង្រឹងនិងធានាការការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុងទឹកដីរបស់ខ្លួន

ខ.នៅក្នុងចំណោម វិធានការការពារទាំងឡាយ ដូចមានចែងក្នុងមាត្រា ២ កថាខណ្ឌទី៣ រដ្ឋភាគីត្រូវកំណត់អត្តសញ្ញាណ និងកំណត់កត្តាផ្សំទាំងឡាយនៃបេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុងទឹកដីរបស់ខ្លួន ដោយមានការចូលរួមពីសហគមន៍ ក្រុមមនុស្ស និង អង្គការក្រៅរដ្ឋាភិបាលដែលមានការពាក់ព័ន្ធផ្ទាល់។

មាត្រា ១២ .- បញ្ជីសារពើភណ្ឌ

១. ដើម្បីធានាឱ្យមានការកំណត់អត្តសញ្ញាណសម្រាប់ការការពារនេះ រដ្ឋភាគីនីមួយៗ ដោយផ្អែកលើស្ថានភាពផ្ទាល់របស់បេតិកភណ្ឌវប្បធម៌អរូបី នោះ ត្រូវធ្វើបញ្ជីសារពើភណ្ឌមួយ ឬច្រើននៃបេតិកភណ្ឌវប្បធម៌អរូបីដែលមាននៅក្នុងទឹកដីរបស់ខ្លួន។ ត្រូវធ្វើបញ្ជីសារពើភណ្ឌទាំងនោះជាប្រចាំ។

២. នៅពេលដែលរដ្ឋភាគីនីមួយៗផ្ញើរបាយការណ៍របស់ខ្លួនតាមពេលកំណត់ទៅជូនគណៈកម្មាធិការ ស្របតាមមាត្រា២៩ រដ្ឋភាគីទាំងនោះ ត្រូវផ្តល់ពត៌មានពិតប្រាកដទាក់ទងទៅនឹងសារពើភណ្ឌទាំងនោះ។

មាត្រា ១៣ .- វិធានការសម្រាប់ការការពារផ្សេងទៀត

ដើម្បីធានាការការពារ ការអភិវឌ្ឍ និងការឱ្យមានតម្លៃចំពោះបេតិកភណ្ឌវប្បធម៌អរូបី រដ្ឋភាគីនីមួយៗត្រូវខិតខំ :

ក.អនុម័តនយោបាយជាទូទៅមួយសម្រាប់ធ្វើឱ្យមានតម្លៃនូវតួនាទីរបស់បេតិកភណ្ឌវប្បធម៌អរូបីនោះ នៅក្នុងសង្គមនិងបញ្ចូលការការពារបេតិកភណ្ឌវប្បធម៌នោះ ទៅក្នុងកម្មវិធីនៃផែនការកម្ម ។

ខ.ចាត់តាំង ឬបង្កើតស្ថាប័នមានសមត្ថកិច្ចមួយ ឬច្រើន ដើម្បីការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលមាន នៅក្នុងទឹកដីរបស់ខ្លួន។

គ.លើកទឹកចិត្តការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស និង សិល្បសាស្ត្រ ក៏ដូចជាការស្រាវជ្រាវវិធីសាស្ត្រទាំងឡាយ សំដៅការពារដោយមានប្រសិទ្ធភាពនូវបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ ជាពិសេសគឺចំពោះបេតិកភណ្ឌវប្បធម៌អរូបីដែលកំពុងឋិតនៅចំពោះមុខគ្រោះថ្នាក់ ។

ឃ.អនុម័តវិធានការគតិយុត្ត បច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុសមស្របសំដៅ ÷

១.ជំរុញការបង្កើតថ្មី ឬពង្រឹងស្ថាប័នបណ្តុះបណ្តាលផ្នែកគ្រប់គ្រងបេតិកភណ្ឌវប្បធម៌អរូបី ហើយនិងការផ្ទេរបន្តនូវបេតិកភណ្ឌទាំងនោះ តាមរយៈវេទិកានិងលំហដើម្បីសំដែងបង្ហាញ ឬការនិយាយអំពី បេតិកភណ្ឌវប្បធម៌ទាំងនោះ។

២.ធានាការបញ្ចូលទៅក្នុងបេតិកភណ្ឌវប្បធម៌អរូបី ដោយគោរពការតាមការប្រតិបត្តិទំនៀមទម្លាប់ដែលគ្រប់គ្រងការរួមបញ្ចូលជាមួយទិដ្ឋភាពដោយឡែកនៃបេតិកភណ្ឌវប្បធម៌ទាំងនោះ។

៣.បង្កើតស្ថាប័នតម្កល់ឯកសារនានាខាងផ្នែកបេតិកភណ្ឌវប្បធម៌អរូបី និងផ្តល់ភាពងាយស្រួលដល់ទំនាក់ទំនងជាមួយស្ថាប័នទាំងនោះ។

មាត្រា ១៤ .- ការអប់រំ ការបំផុសចំណាប់អារម្មណ៍ និងការបង្កើនសមត្ថភាព

តាមមធ្យោបាយសមស្របរដ្ឋភាគីនីមួយៗត្រូវខិតខំ ÷

ក.ធានាឱ្យមានការទទួលស្គាល់ ការគោរព និងការធ្វើឱ្យមានតម្លៃនូវបេតិកភណ្ឌវប្បធម៌អរូបី នៅក្នុងសង្គម ជាពិសេសដោយសារ :

១.កម្មវិធីអប់រំ បំផុសឱ្យមានចំណាប់អារម្មណ៍ និងកម្មវិធីផ្សព្វផ្សាយពត៌មាន ចំពោះសាធារណជនពិសេស គឺយុវជន។

២.កម្មវិធីអប់រំ និងបណ្តុះបណ្តាលដោយឡែកនៅក្នុងសហគមន៍ និងក្រុមមនុស្សដែលមានការពាក់ព័ន្ធ ។

៣.ធ្វើសកម្មភាពពង្រឹងសមត្ថភាពខាងផ្នែកការពារបេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសគឺការគ្រប់គ្រង និង ការស្រាវជ្រាវវិទ្យាសាស្ត្រ ។

៤.ផ្ទេរចំណេះដឹងតាមមធ្យោបាយក្រៅផ្លូវការ ។

ខ.ជូនដំណឹងជាប្រចាំដល់សាធារណជនអំពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើបេតិកភណ្ឌវប្បធម៌ទាំងនេះ ក៏ដូចជា ធ្វើ សកម្មភាពទាំងឡាយ ឈានទៅអនុវត្តតាមអនុសញ្ញានេះ ។

គ.ជំរុញការអប់រំ អំពីការការពារលំហធម្មជាតិ និងទីកន្លែងអនុស្សាវរីយ៍ដែលអត្ថិភាពរបស់វា គឺជាប្រការ ចាំបាច់ សម្រាប់និយាយអំពីបេតិកភណ្ឌវប្បធម៌អរូបី ទាំងនោះ ។

មាត្រា ១៥ .- ការចូលរួមរបស់សហគមន៍ ក្រុមមនុស្ស និង បុគ្គល

នៅក្នុងក្របខណ្ឌនៃសកម្មភាពការពារបេតិកភណ្ឌវប្បធម៌អរូបីនេះ រដ្ឋភាគីនីមួយៗត្រូវខិតខំធានាឱ្យមាន ការចូលរួមដ៏ទូលំទូលាយរបស់សហគមន៍ ពីក្រុមមនុស្ស ហើយពីបុគ្គលជាយថាហេតុ ដែលបានបង្កើត ថែទាំ និងផ្ទេរ បេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ ព្រមទាំងបញ្ចូលពួកគេឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពគ្រប់គ្រង បេតិកភណ្ឌ វប្បធម៌អរូបី នោះ ។

## ជំពូកទី៤

## ការការពារបេតិកភណ្ឌវប្បធម៌អរូបីនៅក្នុងកម្រិតអន្តរជាតិ

មាត្រា ១៦ .- បញ្ជីបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិ

១. ដើម្បីធានាឱ្យមានការមើលឃើញកាន់តែច្បាស់ថែមទៀតអំពីបេតិកភណ្ឌវប្បធម៌អរូបី និងដើម្បីធ្វើឱ្យ មានការយកចិត្តទុកដាក់បន្ថែមទៀត លើសារៈសំខាន់របស់បេតិកភណ្ឌវប្បធម៌ទាំងនោះ ហើយនឹងដើម្បីជួយឱ្យ បានការ សន្ទនាទាំងឡាយនៅក្នុងស្មារតីគោរពដល់វប្បធម៌ចម្រុះ គណៈកម្មាធិការត្រូវបង្កើត ធ្វើជាប្រចាំ ព្រមទាំង បោះពុម្ពផ្សាយ នូវបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិមួយតាមការស្នើរបស់រដ្ឋភាគី ។

២. គណៈកម្មាធិការត្រូវចងក្រងហើយដាក់ជូនសុំការអនុម័តនូវលក្ខខណ្ឌចម្បងសម្រាប់ការបង្កើត ការធ្វើជា ប្រចាំនិង បោះពុម្ពផ្សាយ នូវបញ្ជីតំណាងបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិនេះ ។

មាត្រា ១៧ .- បញ្ជីបេតិកភណ្ឌវប្បធម៌អរូបី ចាំបាច់សម្រាប់ទទួលការការពារជាបន្ទាន់

១. ដើម្បីចាត់វិធានការការពារឱ្យបានសមស្រប គណៈកម្មាធិការត្រូវធ្វើជាប្រចាំនិងបោះពុម្ពផ្សាយនូវបញ្ជី បេតិកភណ្ឌវប្បធម៌អរូបី ដែលត្រូវទទួលការការពារជាបន្ទាន់ ហើយត្រូវចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ តាមសំណើរបស់រដ្ឋភាគីសាមី ។

២. គណៈកម្មាធិការចងក្រងលក្ខខណ្ឌចម្បង ហើយដាក់ជូនសុំការអនុម័តរបស់មហាសន្និបាតសម្រាប់ការធ្វើជា ប្រចាំ និងការបោះពុម្ពផ្សាយនូវបញ្ជីទាំងនេះ ។

៣. នៅក្នុងករណីបន្ទាន់បំផុតដែលលក្ខខណ្ឌសត្យានុម័តត្រូវបានទទួលការយល់ព្រមពីមហាសន្និបាត តាមសំណើរបស់គណៈកម្មាធិការ នោះគណៈកម្មាធិការត្រូវចុះឈ្មោះបេតិកភណ្ឌវប្បធម៌នោះនៅក្នុងបញ្ជីដូចបាន រៀបរាប់នៅក្នុងកថាខណ្ឌទី១ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋភាគីសាមីដែលពាក់ព័ន្ធ ។

មាត្រា ១៨ - កម្មវិធី គម្រោង និងសកម្មភាពក្នុងការការពារ បេតិកភណ្ឌវប្បធម៌អរូបី

១. ឈរលើមូលដ្ឋាននៃសំណើរបស់រដ្ឋភាគី និងអនុលោមទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយ គណៈ កម្មាធិការ និងអនុម័តដោយមហាសន្និបាត នោះគណៈកម្មាធិការត្រូវជ្រើសរើស ក្នុងរយៈពេលជាកំណត់និងជំរុញការ អនុវត្តកម្មវិធី គម្រោងនិងសកម្មភាពមានលក្ខណៈជាតិ អនុតំបន់ ឬថ្នាក់តំបន់ក្នុងការការពារ បេតិកភណ្ឌវប្បធម៌ អរូបីទាំងនោះ ដែលគណៈកម្មាធិការប៉ាន់ប្រមាណថាសមស្របបំផុតទៅនឹងគោលការណ៍ និង គោលដៅរបស់ អនុសញ្ញា និងដោយនៅរក្សាតម្រូវការជាពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

២. ដើម្បីសម្រេចគោលដៅនេះគណៈកម្មាធិការទទួល ពិនិត្យ និងអនុម័តលើសំណើសុំជំនួយឧបត្ថម្ភជា អន្តរជាតិ ដែលរដ្ឋភាគីបានផ្តួចផ្តើមដើម្បីរាក់តែងសំណើទាំងនោះ ។

៣. គណៈកម្មាធិការជួយដំណើរការអនុវត្តកម្មវិធី គម្រោង និងសកម្មភាពទាំងនោះ ដោយធ្វើការផ្សព្វផ្សាយ នូវការប្រតិបត្តិដ៏ប្រសើរតាមបែបបទដែលគណៈកម្មាធិការជាអ្នកកំណត់ ។

## ជំពូកទី៥
## កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ

មាត្រា ១៩ .- កិច្ចសហប្រតិបត្តិការ

១. ដើម្បីសម្រេចគោលដៅរបស់អនុសញ្ញានេះ កិច្ចសហប្រតិបត្តិការអន្តរជាតិ រួមមានការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធ ការផ្តួចផ្តើមគំនិតរួម ព្រមទាំងការបង្កើតឱ្យមានយន្តការ ជាអ្នកផ្តល់ជំនួយទៅឱ្យរដ្ឋភាគីដើម្បី ជួយដល់ការខិតខំការពារបេតិកភណ្ឌវប្បធម៌អរូបីរបស់រដ្ឋភាគីនោះ ។

២. ដោយមិនឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិនៃច្បាប់ជាតិ និងប៉ះពាល់ដល់សិទ្ធិព្រមទាំងការប្រតិបត្តិតាម ទំនៀមទម្លាប់របស់ខ្លួននោះ រដ្ឋភាគីទទួលស្គាល់ថាការការពារបេតិកភណ្ឌវប្បធម៌អរូបី គឺដើម្បីជាផលប្រយោជន៍ ទូទៅរបស់មនុស្សជាតិ ហើយសុខចិត្តធ្វើសហប្រតិបត្តិការកម្រិតទ្វេភាគី កម្រិតអនុតំបន់ កម្រិតតំបន់ និងថ្នាក់ អន្តរជាតិ ។

មាត្រា ២០ .- គោលដៅរបស់ជំនួយអន្តរជាតិ

ជំនួយអន្តរជាតិអាចត្រូវបានផ្តល់ឱ្យសម្រាប់គោលដៅដូចខាងក្រោម :

ក.ការការពារបេតិកភណ្ឌដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី ដែលទាមទារឱ្យមានការការពារជា បន្ទាន់

ខ.ការរៀបចំបញ្ជីសារពើភណ្ឌតាមមាត្រា ១១ និង ១២

គ.ការគាំទ្រដល់កម្មវិធី គម្រោង និងសកម្មភាព ដែលដឹកនាំនៅថ្នាក់ជាតិ ថ្នាក់អនុតំបន់ និងថ្នាក់តំបន់ គឺជាគោលដៅនៃការការពារបេតិកភណ្ឌវប្បធម៌អរូបីទាំងនោះ

ឃ.គោលដៅផ្សេងទៀតដែលគណៈកម្មាធិការយល់ឃើញថាចាំបាច់ ។

មាត្រា ២១ - រូបភាពនៃជំនួយអន្តរជាតិ

ជំនួយដែលគណៈកម្មាធិការផ្តល់ទៅឱ្យរដ្ឋភាគី ត្រូវកំណត់ដោយសេចក្តីណែនាំប្រតិបត្តិដូចមានចែងក្នុងមាត្រា៧ និងតាមការព្រមព្រៀងដូចមានចែងក្នុងមាត្រា២៤ ហើយអាចមានរូបភាពដូចខាងក្រោម :

ក.ការសិក្សាអំពីទិដ្ឋភាពនានានៃការការពារ

ខ.ការផ្តល់អ្នកជំនាញការ និងអ្នកហ្វឹកហាត់

គ.ការបណ្តុះបណ្តាលបុគ្គលិកទាំងអស់ដែលចាំបាច់

ឃ.ការរៀបរៀងបណ្តាវិធានការច្បាប់ និងវិធានការដទៃទៀត

ង.ការបង្កើតនិងការធ្វើអាជីវកម្មផ្នែកហេដ្ឋារចនាសម្ព័ន្ធ

ច.ការផ្តល់ឱ្យនូវគ្រឿងបរិក្ខារ និងចំណេះធ្វើ

ឆ.រូបភាពដទៃទៀតនៃជំនួយខាងហិរញ្ញវត្ថុ និងបច្ចេកទេសរួមទាំងការផ្តល់អំណោយ និងប្រាក់កម្ចីដោយយកអត្រាការប្រាក់ទាបបំផុតនៅក្នុងករណីចាំបាច់ ។

មាត្រា ២២ .- លក្ខខណ្ឌនៃជំនួយអន្តរជាតិ

១. គណៈកម្មាធិការត្រូវបង្កើតនីតិវិធីសម្រាប់ពិនិត្យសំណើសុំជំនួយអន្តរជាតិ ហើយត្រូវបញ្ជាក់ច្បាស់ពីព័ត៌មានអ្វីដែលត្រូវបញ្ចូលនៅក្នុងសំណើទាំងនោះ ដូចជាមធ្យោបាយដែលបានគិតគូរ អន្តរាគមន៍ ជាចាំបាច់ហើយ និងការប៉ាន់ប្រមាណអំពីតម្លៃ ។

២. ក្នុងករណីបន្ទាន់ គណៈកម្មាធិការត្រូវពិនិត្យសំណើសុំជំនួយជាអាទិភាព ។

៣. ដើម្បីឈានដល់ការសម្រេចសេចក្តី គណៈកម្មាធិការត្រូវធ្វើការសិក្សានិងធ្វើការពិគ្រោះគ្នាតាមការចាំបាច់ ។

មាត្រា ២៣ .- សំណើសុំជំនួយអន្តរជាតិ

១. រដ្ឋភាគីនីមួយៗអាចធ្វើសំណើសុំជំនួយអន្តរជាតិទៅគណៈកម្មាធិការ សម្រាប់ការការពារ បេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុងទឹកដីរបស់ខ្លួន ។

២. សំណើបែបនេះក៏អាចដាក់ជូនរួមគ្នាដោយរដ្ឋភាគីពីរ ឬច្រើនក៏បានដែរ ។

៣. សំណើសុំនេះត្រូវបញ្ចូលទាំងព័ត៌មានដូចមានចែងនៅក្នុងមាត្រា២២ កថាខណ្ឌទី១ដោយភ្ជាប់ជាមួយនូវឯកសារចាំបាច់ ។

មាត្រា ២៤ .- តួនាទីរបស់រដ្ឋភាគីដែលទទួលជំនួយ

១. សមស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ ជំនួយអន្តរជាតិដែលផ្តល់ឱ្យត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងទទួលជំនួយជាមួយនិងគណៈកម្មាធិការ ។

២. តាមវិធានទូទៅ រដ្ឋភាគីទទួលជំនួយត្រូវរួមចំណែកតាមកម្រិតនៃមធ្យោបាយរបស់ខ្លួន ក្នុងចំណោមថ្លៃការពារ បន្ទាប់ពីទទួលបាននូវជំនួយអន្តរជាតិ ។

៣. រដ្ឋភាគីទទួលជំនួយផ្ញើជូនគណៈកម្មាធិការវិញ នូវរបាយការណ៍ស្ដីពីការប្រើប្រាស់ជំនួយ ដែលទទួលបាន សម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបី ។

## ជំពូកទី៦
## មូលនិធិនៃបេតិកភណ្ឌវប្បធម៌អរូបី

មាត្រា ២៥ - ប្រភេទ និងប្រភពមូលនិធិ

១. មូលនិធិសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌អរូបី ត្រូវបានបង្កើតឡើងហើយបន្ទាប់មកត្រូវបានគេ ហៅថា " មូលនិធិ ។

២ មូលនិធិ ក្លាយជាមូលនិធិតម្កល់ស្របតាមបទប្បញ្ញត្តិនៃបទបញ្ជាហិរញ្ញវត្ថុរបស់អង្គការយូណេស្កូ ។

៣. ប្រភពរបស់មូលនិធិនេះបានមកពី :

ក.វិភាគទានរបស់រដ្ឋភាគីទាំងអស់

ខ.មូលនិធិសម្រាប់គម្រោងនេះត្រូវបានផ្ដល់ឱ្យដោយមហាសន្និបាតរបស់អង្គការយូណេស្កូ

គ.វិភាគទាន អំណោយ ឬអច្ច័យទានដែលបានមកពី :

១.រដ្ឋដទៃទៀត

២.អង្គការ និងកម្មវិធីរបស់ប្រព័ន្ធនៃអង្គការសហប្រជាជាតិ ជាពិសេសកម្មវិធីរបស់អង្គការសហ-ប្រជាជាតិដើម្បីអភិវឌ្ឍ ក៏ដូចជាអង្គការអន្តរជាតិដទៃទៀត

៣.អង្គការសាធារណៈ ឬ ឯកជន ឬបុគ្គលឯកជនទាំងឡាយ

ឃ.ការប្រាក់បានមកពីប្រភពធនធានរបស់មូលនិធិ

ង.ផលនៃការរៃអង្គាសនិងចំណូលដែលទទួលបានពីពិធីសំដែងនានាដែលធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់ មូលនិធិ

ច.ធនធានផ្សេងទៀត ដែលបានមកតាមការអនុញ្ញាតដោយបទបញ្ជានៃមូលនិធិ ដែលរៀបចំឡើងដោយ គណៈកម្មាធិការ ។

៤. ការប្រើប្រាស់ធនធានដោយគណៈកម្មាធិការត្រូវសម្រេចដោយឈរលើមូលដ្ឋាននៃការតម្រង់ទិសរបស់ មហាសន្និបាត ។

៥. គណៈកម្មាធិការអាចទទួលយកនូវវិភាគទាន និងជំនួយតាមរូបភាពផ្សេងៗទៀត ដែលគេផ្ដល់ឱ្យសម្រាប់ សេចក្ដីត្រូវការជាទូទៅ និងចំគោលដៅសម្រាប់គោលបំណងទូទៅ និង ជាក់លាក់សម្រាប់គម្រោងណាមួយជាក់លាក់ ប្រសិនបើគម្រោងទាំងនោះត្រូវបានទទួលការឯកភាពពីគណៈកម្មាធិការរួចហើយ ។

៦. វិភាគទានសម្រាប់មូលនិធិពុំអាចធ្វើឡើងតាមលក្ខខណ្ឌនយោបាយ សេដ្ឋកិច្ចដែលមានវិសមិតភាព ជាមួយនឹងវត្ថុបំណងរបស់អនុសញ្ញានេះទេ។

មាត្រា ២៦ .- *វិភាគទានរបស់រដ្ឋភាគីទៅក្នុងមូលនិធិ*

១. ដោយមិនឱ្យប៉ះពាល់ដល់វិភាគទានស្ម័គ្រចិត្តជាបន្ថែមនោះ រដ្ឋភាគីនៃអនុសញ្ញាជាអ្នកកាំប់រងបង់វិភាគទានចូលក្នុងមូលនិធិតាមអត្រាភាគរយឯកភាព សម្រាប់រដ្ឋភាគីទាំងអស់រៀងរាល់២ឆ្នាំម្តងយ៉ាងតិច ហើយចំនួនទឹកប្រាក់នៃវិភាគទាននោះត្រូវកំណត់ដោយមហាសន្និបាត ។ សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកតាមសំឡេងភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតដែលមិនបានប្រកាសដូចមានចែងក្នុង កថាខណ្ឌទី២របស់មាត្រានេះ ។ ពុំមានករណីដែលវិភាគទានរបស់រដ្ឋភាគីលើសពី ១ភាគរយនៃវិភាគទានរបស់ខ្លួន ចូលក្នុងថវិកាទៀងទាត់របស់អង្គការយូណេស្កូទេ ។

២. ជានិច្ចកាល រដ្ឋទាំងអស់ដូចបានកំណត់នៅក្នុងមាត្រា៣២ ឬមាត្រា៣៣ នៃអនុសញ្ញានេះ នៅពេលតម្កល់លិខិតតូបករណ៍ឱ្យសច្ចាប័ន ការទទួលយកការយល់ព្រម ឬចូលជាសមាជិកអាចប្រកាសថាពុំមានអ្វីទាក់ទងជាមួយបទប្បញ្ញត្តិនៃកថាខណ្ឌទី១ នៃអនុសញ្ញានេះទេ។

៣. រដ្ឋភាគីមួយរបស់អនុសញ្ញានេះ ដែលបានធ្វើសេចក្តីប្រកាសស្របតាមកថាខណ្ឌទី២នៃមាត្រានេះ នឹងត្រូវខិតខំ ដកយកសេចក្តីប្រកាសនោះមកវិញ ដោយគ្រាន់តែជូនដំណឹងទៅអគ្គនាយក អង្គការយូណេស្កូ ។ ទោះជាយ៉ាងណា ក៏ដោយ ការដកយកសេចក្តីប្រកាសមកវិញនេះ នឹងពុំមានផលប៉ះពាល់ដល់ការបាត់បង់វិភាគទាន ដែលរដ្ឋភាគីនោះត្រូវបង់ទេ ចាប់ពីកាលបរិច្ឆេទនៃការបើកសម័យប្រជុំបន្ទាប់ទៀតរបស់មហាសន្និបាត ។

៤. ដើម្បីឱ្យគណៈកម្មាធិការបានត្រៀមលក្ខណៈរៀបចំប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព វិភាគទានរបស់រដ្ឋភាគីនៃអនុសញ្ញានេះដែលបានធ្វើសេចក្តីប្រកាសហើយដូចមានចែងនៅក្នុងកថាខណ្ឌទី២នៃមាត្រានេះ វិភាគទានទៀងទាត់ គឺយ៉ាងហោចណាស់ក៏ត្រូវបង់នៅរៀងរាល់២ឆ្នាំម្តង ហើយត្រូវឱ្យជិតស្មើនឹងវិភាគទានដែលរដ្ឋទាំងនោះត្រូវបង់ប្រសិនបើគេឋិតនៅក្នុងស្ថានភាពដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

៥. រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ ដែលយឺតយ៉ាវមិនទាន់បានបង់វិភាគទានជាកំហិត ឬដោយស្ម័គ្រចិត្តសម្រាប់ឆ្នាំហើយនិងឆ្នាំចាស់ដែលទើបនឹងផុតទៅ រដ្ឋនោះមិនត្រូវបានចាត់ទុកជាសមាជិកដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសចូលក្នុងគណៈកម្មាធិការបានឡើយ បញ្ញត្តិនេះនឹងមិនយកទៅអនុវត្តចំពោះការបោះឆ្នោតលើកទី១ទេ។ អាណត្តិរបស់រដ្ឋភាគីណាមួយដែលបានក្លាយជាសមាជិករបស់គណៈកម្មាធិការរួចហើយ នឹងត្រូវបញ្ចប់នៅពេលបោះឆ្នោតដូចមានចែងក្នុងមាត្រា ៦ របស់អនុសញ្ញានេះ។

មាត្រា ២៧ .- វិភាគទានដោយស្ម័គ្រចិត្តបន្ថែមទៅក្នុងមូលនិធិ

រដ្ឋភាគីដែលមានបំណងផ្តល់វិភាគទានបន្ថែមទៅលើវិភាគទាន ដូចដែលមានចែងនៅក្នុងមាត្រា២៦នោះត្រូវជូនដំណឹងទៅគណៈកម្មាធិការឱ្យបានឆាប់បំផុតដែលអាចធ្វើបាន ដើម្បីឱ្យគណៈកម្មាធិការរៀបចំប្រតិបត្តិការរបស់ខ្លួនឱ្យបានសមស្របទៅតាមនោះ។

មាត្រា ២៨ .- យុទ្ធនាការនៃការរៃអង្គាសមូលនិធិអន្តរជាតិ

រដ្ឋភាគីត្រូវផ្តល់ជំនួយឱ្យបានច្រើនដែលអាចធ្វើបានដល់យុទ្ធនាការអន្តរជាតិដែលរៀបចំដើម្បីជាប្រយោជន៍ដល់មូលនិធិ ក្រោមការចាត់ចែងរបស់អង្គការយូណេស្កូ ។

## ជំពូកទី៧

## របាយការណ៍

មាត្រា ២៩ .- របាយការណ៍របស់រដ្ឋភាគី

រដ្ឋភាគីត្រូវផ្ញើជូនគណៈកម្មាធិការតាមរូបភាព និងរយៈពេលដែលកំណត់ដោយគណៈកម្មាធិការនូវរបាយការណ៍ស្តីពីបញ្ញត្តិច្បាប់ បទបញ្ជា និងវិធានការផ្សេងៗទៀត សម្រាប់ការប្រតិបត្តិតាមអនុសញ្ញានេះ ។

មាត្រា ៣០ .- របាយការណ៍របស់គណៈកម្មាធិការ

១.ដោយឈរលើមូលដ្ឋាននៃសកម្មភាពរបស់គណៈកម្មាធិការ និងរបាយការណ៍របស់រដ្ឋភាគីដូចមានចែងក្នុង មាត្រា ២៩ គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ទៅជូនរាល់សម័យប្រជុំមហាសន្និបាត ។

២.របាយការណ៍នេះនឹងត្រូវដាក់ជូនមហាសន្និបាតរបស់អង្គការយូណេស្កូ ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

មាត្រា ៣១ .- ទំនាក់ទំនងទៅនឹងការប្រកាសស្នាដៃឯក នៃបេតិកភណ្ឌសំដី និងអរូបីរបស់មនុស្សជាតិ

១.គណៈកម្មាធិការបញ្ចូលទៅក្នុងបញ្ជីនៃបេតិកភណ្ឌវប្បធម៌អរូបី របស់មនុស្សជាតិ នូវអ្វីដែលបានប្រកាស ថាជា ស្នាដៃឯកនៃបេតិកភណ្ឌសំដីនិងអរូបីរបស់មនុស្សជាតិ" មុនពេលអនុសញ្ញានេះចូលជាធរមាន ។

២.ការបញ្ចូលនូវស្នាដៃទាំងនេះ ទៅក្នុងបញ្ជីរាយឈ្មោះនៃបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិនោះមិនត្រូវខុសពីលក្ខខណ្ឌសម្រាប់ការចុះបញ្ជីដែលបានកំណត់ ស្របតាមមាត្រា ១៦ កថាខណ្ឌទី២ទេ ។

៣.គ្មានសេចក្តីប្រកាសណាមួយទៀតដែលត្រូវធ្វើឡើងបន្ទាប់ពីអនុសញ្ញានេះចូលជាធរមានបានឡើយ ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

មាត្រា ៣២ .- ការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម

១. អនុសញ្ញាត្រូវដាក់ជូនសុំសច្ចាប័ន ទទួលយក ឬយល់ព្រមដោយរដ្ឋសមាជិក អង្គការយូណេស្កូ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

២. លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ត្រូវតម្កល់ទុកនៅជាមួយអគ្គនាយក នៃអង្គការយូណេស្កូ ។

មាត្រា ៣៣ .- ការចូលជាសមាជិកនៃអនុសញ្ញា

១. អនុសញ្ញានេះបើកចំហសម្រាប់ការចូលរួមជាសមាជិករបស់រដ្ឋទាំងអស់ ដែលមិនមែនជាសមាជិករបស់អង្គការយូណេស្កូ ហើយដែលត្រូវបានមហាសន្និបាតរបស់អង្គការយូណេស្កូ អំពាវនាវសុំឱ្យចូលរួមក្នុងអនុសញ្ញានេះ ។

២. អនុសញ្ញានេះបើកចំហសម្រាប់ការចូលរួមជាសមាជិករបស់ទឹកដីដែលមានស្វ័យភាពផ្ទៃក្នុងពេញលេញ ហើយដែលត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ប៉ុន្តែមិនទាន់បានទទួលឯករាជពេញលេញតាម សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ១៥១៤(XV) ហើយដែលមានសមត្ថកិច្ច ចំពោះរឿងដែល អនុសញ្ញានេះបានកំណត់ព្រមទាំងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ចុះហត្ថលេខាស្តីពីបញ្ហានេះ ។

៣. លិខិតូបករណ៍នៃការចូលរួមក្នុងអនុសញ្ញាត្រូវតម្កល់ទុកនៅជាមួយអគ្គនាយកនៃអង្គការយូណេស្កូ ។

មាត្រា ៣៤ .- ការចូលជាធរមាន

អនុសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល ៣ខែ ចាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួមក្នុងអនុសញ្ញាទី៣០ ប៉ុន្តែចំពោះតែរដ្ឋទាំងឡាយ ណា ដែលបានតម្កល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួមរបស់ខ្លួន នៅមុន ឬចំកាលបរិច្ឆេទនេះប៉ុណ្ណោះ ។ អនុសញ្ញានេះនឹងចូលជាធរមាន ចំពោះរដ្ឋភាគីដទៃទៀត ក្នុងរយៈពេល ៣ ខែបន្ទាប់ពីការតម្កល់លិខិតូបករណ៍ផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួមក្នុងអនុសញ្ញា របស់រដ្ឋទាំងនោះ ។

មាត្រា ៣៥.- របបរដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោល

បទប្បញ្ញត្តិដូចខាងក្រោមនេះនឹងយកមកអនុវត្តចំពោះរដ្ឋដែលប្រកាន់រដ្ឋធម្មនុញ្ញសហព័ន្ធ ឬមិនមែនរដ្ឋទោល ៖

ក. ចំពោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តឋិតនៅក្រោមសមត្ថកិច្ចនៃនីតិប្បញ្ញត្តិសហព័ន្ធ ឬរឺពោចនីតិប្បញ្ញត្តិកណ្តាល នោះកាតព្វកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធ ឬរដ្ឋាភិបាលកណ្តាលដូចគ្នានឹងកាតព្វកិច្ច របស់រដ្ឋភាគី ដែលមិនមែនជារដ្ឋសហព័ន្ធ ។

ខ. ចំពោះបទប្បញ្ញត្តិនៃអនុសញ្ញានេះ ដែលការអនុវត្តឋិតនៅក្រោមសមត្ថកិច្ចនៃរដ្ឋនីមួយៗ ប្រទេស ខេត្ត ឬតំបន់នីមួយៗដែលមិនឋិតនៅក្រោមរបបរដ្ឋធម្មនុញ្ញសហព័ន្ធ ត្រូវចាត់វិធានការច្បាប់ទាំងឡាយនោះ រដ្ឋាភិបាលសហព័ន្ធត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋប្រទេស ខេត្ត ឬតំបន់ទាំងនោះ អំពី យោបល់ឯកភាពរបស់ខ្លួនលើអនុសញ្ញានេះសម្រាប់ឱ្យអាជ្ញាធរទាំងនោះធ្វើការអនុម័ត ។

មាត្រា ៣៦ .- ការដកខ្លួនចេញ

១. រដ្ឋភាគីនីមួយៗអាចដកខ្លួនចេញពីអនុសញ្ញានេះបាន ។

២. ការដកខ្លួនចេញត្រូវជូនដំណឹងជាលិខិតតូបករណ៍លាយលក្ខណ៍អក្សរទៅតម្កល់ទុកនៅជាមួយអគ្គនាយក នៃអង្គការយូណេស្កូ ។

៣. ការដកខ្លួនចេញ នឹងមានប្រសិទ្ធភាពក្នុងរយៈពេល ១២ខែ បន្ទាប់ពីការទទួលលិខិតូបករណ៍នៃការដកខ្លួននេះ។ ការដកខ្លួនចេញនេះនឹងមិនធ្វើឱ្យប្រែប្រួលដល់កាតព្វកិច្ចផ្នែកហិរញ្ញវត្ថុរបស់រដ្ឋភាគីដែលធ្វើបណ្តើងរហូតដល់កាលបរិច្ឆេទនៃការដកខ្លួនចេញមានអានុភាពតាមច្បាប់ ។

មាត្រា ៣៧ .- តួនាទីរបស់អ្នកតម្កល់ឯកសារ

អគ្គនាយកនៃអង្គការយូណេស្កូ នៅក្នុងឋានៈជាអ្នកតម្កល់អនុសញ្ញានេះ ត្រូវជូនដំណឹងទៅរដ្ឋសមាជិករបស់អង្គការ ទៅរដ្ឋមិនមែនជាសមាជិករបស់អង្គការដូចមានចែងក្នុងមាត្រា ៣៣ ព្រមទាំងទៅអង្គការសហប្រជាជាតិ អំពីការដាក់តម្កល់ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួមក្នុងអនុសញ្ញាដូចមានចែងក្នុង មាត្រា ៣២ និង ៣៣ និងអំពីការដកខ្លួនចេញដូចមានចែងក្នុងមាត្រា ៣៦ ។

មាត្រា ៣៨ .- ការធ្វើវិសោធនកម្ម

១. រដ្ឋភាគីទាំងអស់អាចស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គនាយក។ អគ្គនាយកត្រូវបញ្ជូនសេចក្តីជូនដំណឹងនេះទៅគ្រប់រដ្ឋភាគីទាំងអស់ ។ ប្រសិនបើក្នុងអំឡុងពេល ៦ខែ ចាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសេចក្តីជូនដំណឹងទៅរដ្ឋភាគីទាំងអស់នោះ ហើយមានរដ្ឋភាគីមិនតិចជាងពាក់កណ្តាលឆ្លើយតបគាំទ្រសំណើនោះ លោកអគ្គនាយកត្រូវដាក់សំណើនេះ ជូនសម័យប្រជុំបន្ទាប់របស់ មហាសន្និបាត សម្រាប់ធ្វើការពិភាក្សានិងការអនុម័តជាយថាហេតុ ។

២. ការធ្វើវិសោធនកម្មត្រូវបានអនុម័តដោយសំឡេងភាគច្រើន ២/៣ នៃចំនួនរដ្ឋដែលវត្តមាននិងបោះឆ្នោត ។

៣. វិសោធនកម្មនៃអនុសញ្ញាបន្ទាប់ពីបានអនុម័តរួចហើយនិងត្រូវផ្ញើជូនទៅរដ្ឋភាគីទាំងអស់ដើម្បីផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួម ។

៤. ចំពោះរដ្ឋភាគីទាំងឡាយដែលបានផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួមវិសោធនកម្មនៃអនុសញ្ញា នេះ នឹងចូលជាធរមានក្នុងអំឡុងពេល៣ខែ បន្ទាប់ពីការដាក់តម្កល់លិខិតូបករណ៍ដូចមានចែងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រានេះដោយរដ្ឋភាគីចំនួន២ភាគ៣ ។ បន្ទាប់មក ចំពោះរដ្ឋសមាជិកនីមួយៗ ដែលបានផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬចូលរួមធ្វើវិសោធនកម្ម វិសោធនកម្មនេះនឹងចូលជាធរមាន ក្នុងអំឡុងពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍សំរាប់ការផ្តល់សច្ចាប័ន ទទួលយក យល់ព្រម ឬការចូលរួមរបស់រដ្ឋភាគីនោះ ។

៥. នីតិវិធីដូចមានចែងនៅក្នុងកថាខណ្ឌទី៣និងទី៤មិនយកមកអនុវត្តចំពោះការធ្វើវិសោធនកម្មទៅលើមាត្រា ៥ ដែលទាក់ទងទៅនឹងចំនួនរដ្ឋសមាជិករបស់គណៈកម្មាធិការឡើយ ។ វិសោធនកម្មទាំងនេះនឹងចូលជាធរមាននៅពេលដែលត្រូវបានអនុម័ត ។

៦. រដ្ឋមួយដែលនឹងក្លាយទៅជាភាគីរបស់អនុសញ្ញានេះបន្ទាប់ពីការចូលជាធរមាននៃវិសោធនកម្មដូចមានចែងនៅក្នុងកថាខណ្ឌទី៤ នៃមាត្រានេះ ហើយដែលមិនបានបង្ហាញនូវបំណងផ្សេងពីនេះ និងត្រូវចាត់ទុកថា :

ក.ជាភាគីរបស់អនុសញ្ញាដូចដែលបានធ្វើវិសោធនកម្មនេះ ហើយ

ខ.ជាភាគីរបស់អនុសញ្ញាដែលមិនទាន់ធ្វើវិសោធនកម្ម ចំពោះរដ្ឋភាគីទាំងអស់ដែលមិនជាប់ពាក់ព័ន្ធនឹង ធ្វើវិសោធនកម្មនេះ ។

មាត្រា ៣៩ .- អត្ថបទដែលអាចប្រើការបានដូចគ្នា

អនុសញ្ញានេះត្រូវបានបកប្រែជាភាសា អង់គ្លេស អារ៉ាប់ ចិន អេស្ប៉ាញ បារាំង និង រុស្ស៊ី ដែលអត្ថបទបកប្រែជាភាសាទាំង ៦នេះអាចប្រើការបានដូចគ្នា ។

មាត្រា ៤០ .- *ការចុះបញ្ជីការ*

អនុលោមតាមមាត្រា១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ អនុសញ្ញានេះត្រូវចុះបញ្ជីការនៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ តាមរយៈការស្នើសុំរបស់អគ្គនាយកនៃ អង្គការយូណេស្កូ ។